មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

កំណត់ត្រាសន្ទេប

ការដោះលែងដោយមានលក្ខខណ្ឌលើអ្នកការពារសិទ្ធិមនុស្ស រំលោភលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៤

ខ្លឹមសារសន្ទេប

កំណត់ត្រាសង្ខេបនេះ ពិព័ណ៌នាអំពីការអនុវត្តន៍កើនឡើងជាបន្តបន្ទាប់ប្រកបដោយគ្រោះថ្នាក់របស់រដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) ជុំវិញការបង្ខិតបង្ខំលើអ្នកការពារសិទ្ធិមនុស្ស អ្នកតវ៉ា និងប្រជាពលរដ្ឋសព្វថ្ងៃឲ្យចុះហត្ថលេខាទៅលើលិខិតកិច្ចសន្យាព្រមព្រៀងមិនចូលរួមក្នុងការធ្វើបាតុកម្មនៅពេលអនាគត ឬសកម្មភាពខុសច្បាប់នានាជាថ្នូរទៅនឹងការដោះលែង ឬជាលក្ខខណ្ឌមួយដើម្បីរួចផុតពីការចោទប្រកាន់។ ការអនុវត្តន៍នេះ បង្ហាញពីការរឹតត្បិតមិនស្របច្បាប់ទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និង ជួបប្រជុំរបស់អ្នកការពារសិទ្ធិមនុស្ស និងបុគ្គលឯកជន ហើយជាការរឹតបន្តឹងដ៏គ្រោះថ្នាក់លើបរិយាកាសបំពេញការងាររបស់អ្នកការពារសិទ្ធិមនុស្ស។

ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះគូសបញ្ជាក់ពីករណីដែលកើតឡើងនាពេលកន្លងទៅ និងពេលថ្មីៗនេះរបស់អ្នកការពារសិទ្ធិមនុស្ស អ្នកតវ៉ា និងអ្នកប្រើប្រណាញសង្គមហ្វេសប៊ុកដែលតម្រូវឲ្យចុះហត្ថលេខាលើលិខិតកិច្ចសន្យាព្រមព្រៀងមិនចូលរួមក្នុងសកម្មភាពខុសច្បាប់នានា នៅពេលអនាគត។ ផ្នែកទីពីរបង្ហាញពីអនិត្យានុកូលភាពនៃការអនុវត្តន៍ ដោយសំដៅលើកាតព្វកិច្ចផ្លូវច្បាប់ជាលក្ខណៈអន្តរជាតិរបស់រដ្ឋាភិបាល ចំណែកឯផ្នែកទីបី វិភាគពីផលប៉ះពាល់ដ៏គ្រោះថ្នាក់លើការងាររបស់អ្នកការពារសិទ្ធិមនុស្ស។ ផ្នែកចុងក្រោយធ្វើការបូកសរុបដោយរួមមានអនុសាសន៍មួយចំនួនដាក់ជូនទៅកាន់រដ្ឋាភិបាលដែលមានដូចជា៖

- លុបចោលលិខិតដែលតម្រូវឲ្យចុះហត្ថលេខាបែបនេះ ហើយចាត់ទុកលិខិតទាំងនោះជាមោឃៈ
- បញ្ឈប់ការអនុវត្តន៍ ជុំវិញការបង្ខិតបង្ខំអ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋដែលអនុវត្តសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិ និងខាងការជួបប្រជុំ តាមរយៈការចុះហត្ថលេខាលើលិខិតស្នាមនានាដែលរឹតត្បិតសិទ្ធិរបស់ពលរដ្ឋ ដើម្បីជាថ្នូរនឹងការដោះលែងឬការចោទប្រកាន់។
- បញ្ឈប់ជាបន្ទាន់នូវបម្រាមខុសច្បាប់នាពេលបច្ចុប្បន្នទៅលើការជួបប្រជុំ និងបាតុកម្ម។

- បញ្ឈប់រាល់ការយាយីផ្នែកនយោបាយ និងតាមផ្លូវតុលាការ និងអំពើហិង្សាប្រឆាំងនឹងអ្នកតវ៉ាដោយសន្តិវិធី និងការយាយីលើអ្នកការពារសិទ្ធិមនុស្ស និង
- ទទួលស្គាល់ពីសារៈសំខាន់របស់អ្នកការពារសិទ្ធិមនុស្ស និងអង្គការសិទ្ធិមនុស្ស ព្រមទាំងតម្រូវការក្នុងការការពារពួកគេ។

កំណត់ត្រាសង្ខេបនេះ តាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ (“អង្គការ”) ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។

ការអនុវត្តន៍ប្រកបដោយគ្រោះថ្នាក់

ក្នុងអំឡុងពេលមានបម្រាមនាពេលថ្មីៗនេះទៅលើបាតុកម្មនានា [1] អាជ្ញាធរបានចាត់វិធានការចាប់ខ្លួនអ្នកតវ៉ា ជាពិសេស អ្នកការពារសិទ្ធិមនុស្ស ចាប់ឃុំខ្លួនបណ្តោះអាសន្នដោយពុំមានការចោទប្រកាន់ ហើយបន្ទាប់មក ដាក់លក្ខខណ្ឌដោះលែងដោយតម្រូវឲ្យពួកគេចុះហត្ថលេខាលើលិខិតកិច្ចសន្យាព្រមព្រៀងមិនចូលរួមក្នុងការតវ៉ា ការធ្វើបាតុកម្ម ឬសកម្មភាពខុសច្បាប់នានានៅពេលអនាគត។

ចំនួនកើនឡើងនៃការចាប់ខ្លួនចំពោះអ្នកការពារសិទ្ធិមនុស្សជាច្រើនករណី និងក្រោយមកមានការដោះលែងដោយមានលក្ខខណ្ឌ ចាប់តាំងពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ នៅពេលដែលក្រសួងមហាផ្ទៃបានចេញសេចក្តីថ្លែងការណ៍មួយដែលបញ្ជាក់ថា នឹងមានបម្រាមទៅលើការធ្វើបាតុកម្ម ការប្រមូលផ្តុំ ឬការដើរក្បួននានា ដរាបណា “សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខត្រូវបានស្តារឡើងវិញ”។ បន្ថែមពីនេះ សារព័ត៌មាន *កោះសន្តិភាព* បានរាយការណ៍កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ ថា អភិបាលខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ បានអំពាវនាវឲ្យនគរបាលបំបែកការជួបប្រជុំដែលមានមនុស្សច្រើនជាង១០នាក់។ យោងតាមការសែត *ឌឹ ខេម ប៊ូឌាដេលី* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ រាយការណ៍ថា លោកឧត្តមសេនីយ ខេង ទីតូ អ្នកនាំពាក្យរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស បាននិយាយថា បម្រាមនោះនឹងអនុវត្តរហូតដល់ “សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខត្រូវបានស្តារឡើងវិញ” មានន័យថា បម្រាមនោះនឹងត្រូវបានដកចេញវិញនៅពេលគណបក្សសង្គ្រោះជាតិ (“គ.ស.ជ”) ចូលកាន់កាប់កៅអីនៅក្នុងរដ្ឋសភា។[2]

---

[1] ម.ស.ម.ក “ បម្រាមលើការជួបប្រជុំ ការដើរក្បួន និងបាតុកម្មនៅកម្ពុជា” ((ខែមករា ឆ្នាំ២០១៤)។ អាចរកបានតាមៈ http://bit.ly/1b2MuSO។

[2] មិច ដាវ និងហ្សូមបើ ផេតទើ “ ការហាមប្រាមលើការតវ៉ា រហូតដល់ គណបក្សប្រឆាំងចូលអង្គុយក្នុងសភា” កាសែត ឌឹ ខេមបូឌា ដេលី(ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤)។ អាចរកបានតាមៈ http://bit.ly/1dMw1i7។

បម្រាមនេះ ត្រូវបានអនុវត្តបន្ទាប់ពីកម្ពុជាជួបប្រទះនឹងព្រឹត្តិការណ៍ប៉ះទង្គិចដោយហិង្សាកាលពីថ្ងៃទី២ ទី៣ និងថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ រវាងកងកម្លាំងសន្តិសុខ និងអ្នកតវ៉ារបស់ គ.ស.ជ និងអ្នកតវ៉ាដែលជាកម្មកររោងចក្រ ដែលកម្មករទាំងនេះ តវ៉ាទាមទារតម្លើងប្រាក់ឈ្នួលអប្បបរមា។ ការប្រើកម្លាំងដ៏ហួសហេតុរបស់កងកម្លាំងសន្តិសុខទៅលើអ្នកតវ៉ា បាននាំឲ្យមានមនុស្សស្លាប់យ៉ាងតិចបួននាក់ និងមានអ្នករងរបួសជាច្រើននាក់ និងមានការចាប់ខ្លួនមនុស្សចំនួន២៣នាក់។

បម្រាមនោះត្រូវបានអនុវត្តសាកល្បងលើកដំបូងនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤ ទៅលើសកម្មជនការពារសិទ្ធិមនុស្សចំនួនប្រាំរូបមកពីសហគមន៍បឹងកក់ រួមមាន៖ អ្នកស្រី ទេព វន្នី អ្នកស្រី យ៉ោម បុប្ផា អ្នកស្រី បូ ធវី អ្នកស្រី សុង ស្រីលាភ និងអ្នកស្រី ផាន់ ឈុនរ៉ែត។ នៅម៉ោង ៨:០០នាទីព្រឹក ពួកគេបានដើរហែក្បួនទៅកាន់ស្ថានទូតបារាំងដើម្បីស្នើឲ្យមានការដោះលែងលោក វ៉ន់ ពៅ ដែលជាសកម្មជនការពារសិទ្ធិមនុស្ស និងអ្នកតវ៉ាដោយសន្តិវិធីចំនួន៩នាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍ ទី២ ខែមករា ឆ្នាំ២០១៤។ [3] សកម្មជនបឹងកក់ទាំងប្រាំនាក់នោះត្រូវបានចាប់ខ្លួនដោយនគរបាលនៅម៉ោងប្រហែល៨:៤០នាទីព្រឹក និងបានបញ្ជូនទៅកាន់ស្នងការនគរបាលក្រុងភ្នំពេញ។ ពួកគេត្រូវបានដោះលែងមកវិញនៅម៉ោង ៤:៤៥នាទីល្ងាច បន្ទាប់ពីពួកគេបានយល់ព្រមចុះហត្ថលេខាលើលិខិតមួយច្បាប់ ដោយបញ្ជាក់ថា ពួកគេនឹងមិនចូលរួមជាបណ្តោះអាសន្នក្នុងការតវ៉ា ឬសកម្មភាពខុសច្បាប់នានាទៀតទេ។[4]

ការចាប់ខ្លួនផ្សេងទៀតបានបន្តធ្វើឡើងកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ នៅពេលដែលលោក សុខ ឈុនអឿង ប្រធានស្តីទីនៃសមាគមប្រជាធិបតេយ្យ ឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (“អាយឌ”) ត្រូវបានចាប់ខ្លួនខណៈពេលដែលលោកកំពុងតវ៉ាឲ្យមានការដោះលែងមនុស្សទាំង២៣នាក់ ដែលត្រូវបានអាជ្ញាធរចាប់ឃុំខ្លួនតាំងពីការប៉ះទង្គិចដោយហិង្សានៅថ្ងៃទី២ និងថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។ លោកត្រូវបានឃុំខ្លួននៅស្នងការនគរបាលក្រុងពេញមួយយប់ និងបានដោះលែងមកវិញនៅម៉ោងប្រហែល ១០:០០ នៅព្រឹកបន្ទាប់ ក្រោយពីបានចុះហត្ថលេខាលើលិខិតស្នាមស្រដៀងគ្នានេះ។[5]

ពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ សកម្មជនសិទ្ធិមនុស្ស និងអ្នកតវ៉ាសន្តិវិធី១១នាក់ ត្រូវបានកងសន្តិសុខខ័ណ្ឌដូនពេញចាប់ខ្លួនបណ្តោះអាសន្ន ហើយបានបញ្ជូនសកម្មជនទាំងនោះទៅកាន់ស្នងការនគរបាលក្រុងភ្នំពេញ។ ពួកគេទាំងនោះរួមមាន សកម្មជនសហគមន៍បឹងកក់ គឺអ្នកស្រី ទេព

---

[3] ម.ស.ម.ក “ការចាប់ខ្លួន និងការចោទប្រកាន់លើអ្នកការពារសិទ្ធិមនុស្សគឺ លោក វ៉ន់ ពៅ ប្រធាន សមាគមអាយឌ” (ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤)។ អាចរកបានតាម៖ http://bit.ly/1dMuwAD។

[4] ម.ស.ម.ក សហព័ន្ធអន្តរជាតិ ដើម្បីសិទ្ធិមនុស្ស អង្គការប្រឆាំងទារុណកម្មអន្តរជាតិ អង្គកា លីកាដូ “ប្រទេសកម្ពុជា៖ ការយោយីការចាប់ខ្លួន និងការឃុំខ្លួន លើសកម្មជនការពារសិទ្ធិមនុស្សនៅតែកើតមានបន្ត” (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1dKmIiC។

[5] ឃុត សុភ័ក្រ ចរិយា និងស៊ាន ទីហាន “ ថ្នាក់ដឹកនាំសហជីព ត្រូវបានដោះលែង” កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២០ ខែមករា ឆ្នាំ ២០១៤)។ អាចរកបានតាម៖ http://bit.ly/1coBosf។

វន្នី អ្នកស្រី យ៉ោម បុប្ផា អ្នកស្រី សុង ស្រីលាភ អ្នកស្រី ផាន់ ចាន់រ៉ែត អ្នកស្រី ផួង សុភាព អ្នកស្រី អ៊ឹម ស្រីតូច អ្នកស្រី បៅ សោភា និងអ្នកស្រី ងួន គឹមឡាង ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ លោក រ៉ុង ឈុន សមាជិកសហព័ន្ធសហជីពកម្ពុជា អ្នកស្រី ជាង ធីតា និងមន្ត្រីទំនាក់ទំនងនៃអង្គការសិទ្ធិលំនៅដ្ឋាន កញ្ញា ឡុង គឹមហៀង។ ការចាប់ខ្លួនអ្នកទាំង៦នាក់ដំបូងបានកើតឡើងនៅខាងមុខស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ខណៈពេលមានបាតុកម្មដើម្បីដាក់ញត្តិស្នើឲ្យមានការដោះលែងមនុស្សទាំង២៣ ដែលត្រូវបានអាជ្ញាធរចាប់ខ្លួន។ មនុស្សប្រាំនាក់ផ្សេងទៀត ត្រូវបានចាប់ខ្លួនប្រហែលជា ១០នាទី ក្រោយមក ខណៈដែលពួកគេធ្វើដំណើរឆ្ពោះទៅកាន់ស្ថានទូតបារាំង។ មនុស្សទាំង១១នាក់នោះត្រូវបានដោះលែងវិញនៅពេលរសៀល បន្ទាប់ពីបានចុះហត្ថលេខាលើលិខិតស្នាមមួយ ដោយបញ្ជាក់ថា ពួកគេនឹងមិនញុះញង់ ឬចូលរួមនៅក្នុងសកម្មភាពខុសច្បាប់ ឬបាតុកម្មនានាទៀតទេ។[6]

នេះពុំមែនជាលើកទីមួយទេ ដែលរដ្ឋាភិបាលបានតម្រូវឲ្យអ្នកការពារសិទ្ធិមនុស្សចុះហត្ថលេខាបោះបង់សិទ្ធិតវ៉ារបស់ខ្លួននៅពេលអនាគត។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១ សមាជិក១១នាក់មកពីសហគមន៍បឹងកក់ត្រូវបានចាប់ខ្លួន ខណៈពេលធ្វើបាតុកម្មដោយសន្តិវិធីមួយដើម្បីតវ៉ានឹងការបំផ្លិចបំផ្លាញលំនៅដ្ឋានរបស់ពួកគេ។ យោងតាមស្នងការនគរបាលក្រុងភ្នំពេញ លោក ទូច ណារ៉ុថ "អ្នកភូមិដែលត្រូវចាប់ខ្លួនទាំងនោះ ត្រូវបានបង្គាប់ឲ្យចុះហត្ថលេខាលើកិច្ចសន្យាមួយដោយសន្យាថានឹងឈប់តវ៉ាដែលបង្កអោយខូចសណ្តាប់ធ្នាប់សាធារណៈ និងបញ្ឈប់ការប្រើអំពើហិង្សានិងការឈ្លោះប្រកែកជាមួយនគរបាល។[7]

លើសពីនេះទៅទៀត កាលថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ លោក រ៉ុង បញ្ញា ជាតំណាងនៃសហភាពសហជីពកម្ពុជា បានចូលរួមក្នុងការតវ៉ាមួយដែលមានកម្មករកាត់ដេរចូលរួមប្រមាណ ៥០០នាក់ មកពីរោងចក្រ តៃ ណាន នៅឯទីលានប្រជាធិបតេយ្យ កណ្តាលរាជធានីភ្នំពេញ។ កម្មករបានប្រមូលផ្តុំគ្នាដើម្បីដាក់ញត្តិទៅកាន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលរៀបរាប់ពីការទាមទារលក្ខខណ្ឌនានារួមទាំងការតម្លើងប្រាក់ឈ្នួល ។ បាតុកម្មនោះបាននាំទៅរកអំពើហិង្សា បន្ទាប់ពីប៉ូលីសបង្ក្រាបកូដកម្មជាច្រើនរយនាក់មកដល់ ដែលនាំឲ្យប៉ូលីសមានការវាយដំនឹងដំបង និងចាប់ខ្លួនលោក រ៉ុង បញ្ញា បញ្ជូនតាមឡានទៅកាន់ការិយាល័យនៃស្នងការនគរបាលរាជធានីភ្នំពេញ។[8] លោក បញ្ញា ត្រូវបានដោះលែងមកវិញបន្ទាប់ពីបានផ្តិត

---

[6] ម.ស.ម.ក "បន្តការចាប់ខ្លួនជាបណ្តោះអាសន្នលើសកម្មជនការពារសិទ្ធិមនុស្ស និងបម្រាមលើបាតុករ" (សេចក្តីប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិ និង សេរីភាពខាងការបញ្ចេញមតិ) (ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1dMv9Ku។

[7] ឃុត សុភ័ក្រ ចរិយា ការតវ៉ារបស់អ្នកភូមិបឹងកក់បានឈានដល់ការបង្ហូរឈាម (ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១)។ អាចរកបានតាមរយៈ:http://bit.ly/LiMLrd។

[8] ម.ស.ម.ក "ការឆ្លើយតបដោយហិង្សាទៅលើការតវ៉ារបស់កម្មករ" (សលាកប័ត្រព័ត៌មាន) (ខែកក្កដា) (ឆ្នាំ២០១២)។ អាករកបានតាមរយៈ:http://bit.ly/1dKrA7u។

មេដៃលើឯកសារមួយច្បាប់ដែលបានបញ្ជាក់ថាលោកពិតជាបានញុះញង់នាំឲ្យមានការតវ៉ា[9] ហើយលោកនឹងមិនចូលរួមក្នុងសកម្មភាពនានា នៅពេលខាងមុខ ដូចជាចូលរួមក្នុងបាតុកម្មជាដើម។

លើសពីនេះទៅទៀត ការអនុវត្តន៍នេះ មិនត្រឹមតែអនុវត្តទៅលើអ្នកតវ៉ា និងអ្នកការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានអាជ្ញាធរអនុវត្តដើម្បីរឹតត្បិតសេរីភាពខាងការបញ្ចេញមតិនៅលើបណ្តាញសង្គមហ្វេសប៊ុកទៀតផង។ លោក ចិត្ត សុវិជ្ជា ត្រូវបានកងរាជអាវុធហត្ថកោះហៅនិងទទួលការគំរាមចោទប្រកាន់ពីបទបរិហារកេរ្តិ៍ បន្ទាប់ពីលោកវិះគន់ទៅលើលោកវរៈសេនីយឯក អៀង វណ្ណឌី នៅលើហ្វេសប៊ុករបស់ខ្លួន កាលពីខែវិច្ឆិកា ឆ្នាំ២០១៣។ លោកមិនត្រូវបានចោទប្រកាន់ ដោយសារលោកបានយល់ព្រមចុះហត្ថលេខាលើលិខិតសូមអភ័យទោសចំពោះមតិយោបល់របស់លោក ។[10] ករណីស្រដៀងគ្នានេះ លោក កែល ភារុណ បានបង្ហោះរឿងរ៉ាវរបស់លោកពាក់ព័ន្ធជាមួយអាជ្ញាធរម្នាក់ក្នុងករណីបទល្មើសចរាចរនៅលើទំព័រហ្វេសប៊ុករបស់ខ្លួន ក្នុងខែមករា ឆ្នាំ២០១៣ ហើយលោកត្រូវបាននគរបាលកោះហៅឲ្យចូលខ្លួនឆ្លើយបំភ្លឺនៅប៉ុស្តិ៍នគរបាលពាក់ព័ន្ធនឹងករណីបរិហារកេរ្តិ៍នៅខែបន្ទាប់។ បទចោទប្រកាន់មិនត្រូវបានចាត់ការបន្តបន្ទាប់ពីលោកយល់ព្រមមិនចូលរួមនៅក្នុងសកម្មភាពស្រដៀងគ្នានេះនៅពេលអនាគត។[11]

ការបង្ខិតបង្ខំឲ្យចុះហត្ថលេខាលើលិខិតស្នាម ដោយកម្រិតលើសកម្មភាពនានារបស់អ្នកការពារសិទ្ធិមនុស្សពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពនៃការជួបប្រជុំ កំពុងតែឈានទៅក្នុងលំនាំដ៏គ្រោះថ្នាក់មួយ។ ករណីនេះ មិនប្រាកដថារដ្ឋាភិបាលនឹងយកមកអនុវត្តនៅពេលអនាគតឬយ៉ាងណានោះទេ ប៉ុន្តែអំពើទាំងនេះបានបង្ហាញឲ្យឃើញពីការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្ស អ្នកតវ៉ា និងជាចេតនារារាំង និងជាបរិយាកាសអយុត្តិធម៌ ដែលបង្ហាញពីការរំលោភបំពានសិទ្ធិមនុស្សជាមូលដ្ឋាន។

ការអនុវត្តន៍ពុំត្រឹមត្រូវតាមច្បាប់

អនិត្យានុកូលភាពជុំវិញការចុះហត្ថលេខាដោយបង្ខំ និងកិច្ចសន្យាដែលមានវិការៈ មានគោលបំណងរឹតត្បិតហួសហេតុទៅលើការប្រើប្រាស់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី។ អ្នកការពារសិទ្ធិមនុស្ស ត្រូវបានបង្ខំឲ្យចុះហត្ថលេខាលើលិខិតស្នាមដើម្បីបោះបង់សិទ្ធិចូលរួមបាតុកម្មនានា ដែលជាលក្ខខណ្ឌមួយជាថ្នូរនឹងការដោះលែង ឬមិនធ្វើការចោទប្រកាន់លើពួកគេ។ ប្រការនេះ បាន

---

[9] សែន ដាវិត " តំណាងសហជីពបានត្រូវនគរបាលបង្ខំឲ្យសារភាព" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២)

[10]"អ្នកប្រើប្រាស់ហ្វេសប៊ុកដែលត្រូវបានអាជ្ញាធរចាប់ខ្លួនពីបទបរិហារកេរ្តិ៍នោះត្រូវដោះលែងវិញ" (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣) អាចរកបានតាម៖ ។ http://bit.ly/1f6m4jG។

[11]ករណីសិក្សា "លោក កែល ភារុណ" (ខែមិនា ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/1bPUYIR និងរបាយការណ៍របស់ ម.ស.ម.ក ស្តីពី ការគាបសង្កត់ការបញ្ចេញមតិ៖ ស្ថានភាពសេរីភាពបញ្ចេញមតិនៅកម្ពុជា (ខែកញ្ញា ឆ្នាំ២០១៣ (ទំព័រ ២៨)។ អាចរកបានតាម៖http://bit.ly/LmcXRV ។

រារាំងពួកគេមិនឲ្យអនុវត្តនូវសិទ្ធិមនុស្សជាមូលដ្ឋាននៃសេរីភាពខាងការការបញ្ចេញមតិ និងការជួបប្រជុំ និងសិទ្ធិជាអ្នកការពារសិទ្ធិមនុស្ស ដោយទទួលនូវការគំរាមកំហែង ប្រសិនបើពួកគេជ្រើសរើសមធ្យោបាយតវ៉ា។

សិទ្ធិសេរីភាពខាងការជួបប្រជុំ ត្រូវបានលើកស្ទួយ និងការពារតាមមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ដែលចែងថា ប្រជាពលរដ្ឋខ្មែរ “*មានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពក្នុងការបោះពុម្ពផ្សាយ សេរីភាពក្នុងការប្រជុំ*”។ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញក៏បានចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេស។ បន្ថែមពីនេះទៀត មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានដាក់បញ្ចូលនូវសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (“ស.ស.ស.ម”) ព្រមទាំងអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”) ចូលទៅក្នុងច្បាប់ជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២។ កាតព្វកិច្ចអនុវត្តដោយផ្ទាល់នូវច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងតុលាការកម្ពុជាត្រូវបានបញ្ជាក់បន្ថែមទៀតតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។[12]

ដូច្នេះ រដ្ឋាភិបាលស្ថិតនៅក្រោមកាតព្វកិច្ចច្បាប់ ដើម្បីអនុវត្តន៍តាមបទប្បញ្ញត្តិនៃ “ក.អ.ស.ព.ន” និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនានា។ មាត្រា ២១ នៃ ក.អ.ស.ព.ន បានកំណត់ឲ្យការពារសិទ្ធិជួបប្រជុំដោយសន្តិវិធី ដោយអនុញ្ញាតឲ្យ *មានការរឹតត្បិតសិទ្ធិណា “ដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីជាប្រយោជន៍ដល់សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខមាលភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ”*។

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (“អ.ស.ប”) នៅក្នុងវិចារណកថាទូទៅលេខ៣១[13] ចែងថា “*នៅពេលដែលការរឹតត្បិតត្រូវបានធ្វើឡើង រដ្ឋត្រូវតែបង្ហាញពីភាពចាំបាច់របស់ខ្លួន និងចាត់វិធានការដែលសមាមាត្រទៅនឹងគោលបំណងច្បាប់ ដើម្បីជានានូវកិច្ចការពារដល់សិទ្ធិដែលមានចែងក្នុងអនុសញ្ញាឲ្យបានខ្ជាប់ខ្ជួន និងប្រកបដោយប្រសិទ្ធភាព*”។ ការរឹតត្បិតលើសិទ្ធិសេរីភាពជួបប្រជុំ អាចអនុញ្ញាតឲ្យធ្វើទៅបានតែក្នុងកាលៈទេសៈចង្អៀតតែប៉ុណ្ណោះ។ ប៉ុន្តែ លិខិតដែលអាជ្ញាធរតម្រូវឲ្យអ្នកការពារសិទ្ធិមនុស្ស និងអ្នកតវ៉ាចុះហត្ថលេខានោះគឺមានលក្ខណៈទូលំទូលាយហួសប្រមាណ។

លិខិតហាមឃាត់អ្នកការពារសិទ្ធិមនុស្ស ដើម្បីបញ្ឈប់ការធ្វើបាតុកម្មបន្តទៅទៀត គឺជាសេចក្តីថ្លែងការណ៍ទូលំទូលាយមួយ។ គ្មានបទប្បញ្ញត្តិណាមួយស្តីពីប្រភេទនៃការតវ៉ាដែលមិនអនុញ្ញាតឲ្យអ្នកការពារ

---

[12]ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧(ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

[13] គណៈកម្មាធិការសិទ្ធិមនុស្ស “វិចារណកថាលេខ៣១ [៨០] ប្រភេទនៃកាតព្វកិច្ចច្បាប់ទូទៅដាក់កំណត់លើរដ្ឋភាគីនៃកតិកាសញ្ញា” ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ /គ/២១/កែប្រែ.១/ បន្ថែម ១៣ (ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤) អាចរកបានតាម៖) http://bit.ly/LmkEHB។

សិទ្ធិមនុស្សចូលរួម ឬថាតើការហាមឃាត់នោះអនុវត្តក្នុងរយៈពេលយូរប៉ុណ្ណានោះទេ។ ហេតុដូច្នោះ លិខិតនោះចាត់ទុកថាជាការរឹតត្បិតលើសិទ្ធិសេរីភាពខាងការជួបប្រជុំយ៉ាងពិតប្រាកដ ដែលជាការរឹតត្បិតមួយពុំសមហេតុផល និងហួសហេតុពេក។ ម្យ៉ាងវិញទៀត ខណៈពេលដែលការរឹតត្បិតនោះអាចចាត់ទុកថាត្រឹមត្រូវ និងចាំបាច់ដោយផ្អែកលើហេតុផលក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ជាពិសេស ធ្វើឡើងភ្លាមៗ បន្ទាប់ពីព្រឹត្តិការណ៍ហិង្សាកើតឡើង ទង្វើបែបនេះនឹងត្រូវបញ្ចប់ទៅវិញតាមពេលវេលាដែលកន្លងផុតទៅ។ ចំពោះហេតុផលនេះ ការរឹតត្បិតណាមួយទៅលើសេរីភាពជួបប្រជុំដោយសន្តិវិធី គួរតែត្រូវកំណត់ឲ្យបានតឹងរឹងទាន់ពេលវេលា ក្នុងស្ថានភាពចាំបាច់។

ជាងនេះទៅទៀត ករណីបង្កឲ្យមានសកម្មភាពខុសច្បាប់ណាមួយក៏អាចនាំឲ្យមានការដៃជែកដៃញ ដោលផងដែរ។ ឧទាហរណ៍ ក្នុងអំឡុងពេលមានការចាប់ខ្លួនកាលនៅខែមករា ឆ្នាំ២០១៤ ដូចបានរៀបរាប់មកពីខាងលើ រដ្ឋាភិបាលបានចាត់ទុកការតវ៉ានានាជាអំពើខុសច្បាប់ ដោយសារ តែបម្រាមនោះពុំត្រឹមត្រូវតាមច្បាប់ស្តីពីការជួបប្រជុំ។ យោងតាមច្បាប់អន្តរជាតិ អ្នកតវ៉ាដោយសន្តិវិធីគឺកំពុងអនុវត្តសិទ្ធិជួបប្រជុំដោយស្របច្បាប់របស់ខ្លួន ចំណែកឯរដ្ឋាភិបាលកម្ពុជាបានរឹតត្បិតពុំត្រឹមត្រូវលើសិទ្ធិនេះទៅវិញ។ ដូច្នេះ នៅពេលដែលរដ្ឋាភិបាលកំណត់សកម្មភាពណាមួយថា "ខុសច្បាប់" ការរឹតត្បិតនោះទៅវិញទេដែលជាអំពើពុំស្របច្បាប់។

ម្យ៉ាងវិញទៀត លិខិតនេះគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវទេ។ ការចុះហត្ថលេខាធ្វើឡើងក្រោមការគំរាមកំហែង និងការគាបសង្កត់ ដែលជារឿយៗ ធ្វើនៅប៉ុស្តិ៍នគរបាល ខណៈដែលអ្នកការពារសិទ្ធិមនុស្សកំពុងតែជាប់ឃុំ។ ពួកគេទទួលរងនូវការគំរាមកំហែង ជាថ្នូរនឹងការរួចផុតពីការចាប់ខ្លួន និងការរចោទប្រកាន់ ដូច្នេះហើយការសន្យាទាំងនោះត្រូវចាត់ទុកជាមោឃៈ ហើយមិនអាចចាត់ទុកថាជា "កិច្ចសន្យា" រវាងអាជ្ញាធរ និងបុគ្គលណាមួយនោះទេ ហើយក៏ពុំមានកាតព្វកិច្ចផ្លូវច្បាប់ត្រូវអនុវត្តនោះដែរ។

ការអនុវត្តន៍ប្រកបដោយគ្រោះថ្នាក់ចំពោះអ្នកការពារសិទ្ធិមនុស្ស

ការអនុវត្តន៍បែបនេះ មានផលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើការងាររបស់អ្នកការពារសិទ្ធិមនុស្សដែលធ្វើការរឹតត្បិតលើលទ្ធភាពដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្ហាញដែរថា ការគំរាមកំហែងចាប់ខ្លួនខាងលើ គឺកំពុងតែស្ថិតនៅជុំវិញខ្លួនអ្នកការពារសិទ្ធិមនុស្សជានិច្ច។ មាត្រា ៥ នៃសេចក្តីប្រកាស ស្តីពីអ្នកការសិទ្ធិមនុស្ស[14] របស់ អ.ស.ប ទទួលស្គាល់នូវសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី ហើយអ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សរបស់អង្គការ អ.ស.ប ចាត់ទុកសិទ្ធិជួបប្រជុំដោយសន្តិវិធីមានសារៈសំខាន់ចំពោះអ្នកការពារសិទ្ធិមនុស្ស ដែលពួកគេកំពុងធ្វើការងារនៅតាមតំបន់

[14] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៥៣/១៤៤ សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល នីតិបុគ្គល និងស្ថាប័នអង្គការក្នុងសង្គម ក្នុងការងារលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល (ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៨)អាចរកបានតាមរយៈhttp://bit.ly/1fbj99p។

តាមប្រទេស និងទូទាំងពិភពលោក ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ប្រសិនបើគ្មានសិទ្ធិនេះទេ អ្នកការពារសិទ្ធិមនុស្សនឹងត្រូវអាជ្ញាធរតឹតត្បិតចំពោះលទ្ធភាពរបស់ខ្លួន ក្នុងការបំពេញនូវតួនាទីដ៏សំខាន់ក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។[15]

ជាងនេះទៅទៀត ការអនុវត្តន៍នេះបង្ហាញពីការគំរាមចាប់ខ្លួនជាបន្តបន្ទាប់ចំពោះសកម្មជនការពារសិទ្ធិមនុស្សយ៉ាងពិតប្រាកដ។ យោងទៅលើការកត់សម្គាល់របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរបស់ អ.ស.ប បញ្ជាក់ថា «*នេះជារឿងធម្មតាដែលអាជ្ញាធររបស់រដ្ឋមួយចំនួនជម្រុញអ្នកការពារសិទ្ធិមនុស្សឲ្យធ្លាក់ចូលក្នុងអំពើមួយដែល "មិនស្របតាមផ្លូវច្បាប់" ហើយប្រើប្រាស់ភាពមិនស្របច្បាប់នេះជាមូលដ្ឋានសម្រាប់ធ្វើការចាប់ខ្លួន ឃុំខ្លួន និងចោទប្រកាន់ជាបន្តបន្ទាប់*»។[16] ការអនុវត្តន៍ដោយការប្រមូលហត្ថលេខាជាមធ្យោបាយមួយដ៏គ្រោះថ្នាក់។ ដរាបណាសកម្មជនការពារសិទ្ធិមនុស្សបន្តអនុវត្តសិទ្ធិខាងការជួបប្រជុំ និងសិទ្ធិសម្តែងមតិរបស់ខ្លួន អ្នកទាំងនោះនឹងនៅតែជួបអំពើអយុត្តិធម៌ ហើយបង្ខំចិត្តទទួលយក "*កិច្ចសន្យា*" ដែលតែងតែស្ថិតនៅជុំវិញសកម្មភាពតវ៉ារបស់ខ្លួនជានិច្ច។ ហត្ថលេខាទាំងនោះត្រូវធ្វើឡើងដោយបង្ខំ មានវិការៈ និងផ្តល់យុត្តិកម្មដល់រដ្ឋាភិបាលក្នុងការចាប់ខ្លួន
ចំពោះសកម្មជនទាំងនេះក្នុង ពេលអនាគត។

ការគំរាមចាប់ខ្លួនជាអចិន្ត្រៃយ៍គឺជាការផ្ទុយទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្តីពីការការពារសិទ្ធិមនុស្សក្នុងបរិបទសិទ្ធិនៃការតវ៉ាដែលចែងថា "*ជនគ្រប់រូបត្រូវតែអាចទាមទារការខូចខាត ឬសេចក្តីប្រាថ្នាដោយសន្តិវិធី រួមទាំងការតវ៉ាជាសាធារណៈ ដោយពុំមានការភ័យខ្លាចពីការបង្កឲ្យមានរបួសការវាយដំ ការចាប់ខ្លួនដោយអំពើចិត្ត និងការឃុំខ្លួន ការទទួលទារុណកម្ម ការសម្លាប់ ឬប្រឈមនឹងការបាត់ខ្លួនដោយបង្ខំ*"។ [17] បន្ថែមពីនេះទៀត រាល់ការចាប់ខ្លួននាពេលអនាគតដែលនិងត្រូវធ្វើឡើងដោយផ្អែកតែទៅលើលិខិតទាំងនោះ គួរត្រូវបានចាត់ទុកថា ជាការឃុំខ្លួនតាមអំពើចិត្ត និងខុសច្បាប់។[18]

---

15 មហាសន្និបាតរបស់អង្គការសហប្រជាជាតិ រាយការណ៍ដោយតំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកផ្នែកសិទ្ធិអ្នកការពារសិទ្ធិមនុស្ស ឯកសាររបស់ អ.ស.ប ក/៦១/៣១២ (ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៦) កថាខ័ណ្ឌទី ៧៦ និងសេចក្តីណែនាំ អាចរកបានតាមរយៈ:http://bit.ly/1fbiAN0 ។

16 ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិ "អ្នកការពារសិទ្ធិមនុស្ស៖ ការពារសិទ្ធិដើម្បីការពារលើសិទ្ធិមនុស្ស" (សលាកប័ត្រព័ត៌មាន លេខ ២៩) អាចរកបានតាម៖http://bit.ly/1iFTNUY។

17 សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស "ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅក្នុងបរិបទនៃការតវ៉ាដោយសន្តិវិធី" ក/សេចក្តីសម្រេច/១៩/ ៣៥ (ថ្ងៃទី១៨ មេសា ឆ្នាំ២០១២) អាចរកបានតាម៖ http://bit.ly/1llo3qn។

18 វិចារណៈកថាទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ៣៥ (មាត្រា ៩ សេរីភាព និងសន្តិសុខបុគ្គល) (ឆ្នាំ២០១៣) ឯកសាររបស់ អ.ស.ប កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ /គ/១០៧/សេចក្តីសម្រេចលេខ៣ កថាខ័ណ្ឌ១៧ គណៈកម្មាធិការសិទ្ធិមនុស្ស រួមទាំង ការស៊ើបអង្កេតទៅលើប្រទេសកាណាដា (ឆ្នាំ២០០៦) ឯកសាររបស់ អ.ស.ប កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ/គ/កថាខ័ណ្ឌទី២០ គណៈកម្មាធិការសិទ្ធិមនុស្ស រួមទាំង ការស៊ើបអង្កេតទៅលើប្រទេសមូលដ្ឋា (ឆ្នាំ ២០០៦) កន.ព.ស. ឯកសាររបស់ អ.ស.ប កថាខ័ណ្ឌទី៨ អាចរកបានតាម៖ http://bit.ly/1fbdi3S ។

សេចក្តីសន្និដ្ឋាន

តាមរយៈការអនុវត្តន៍នេះ រដ្ឋាភិបាលមិនត្រឹមតែរំលោភលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិជួបប្រជុំរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្អាក់ទឹកចិត្ត និងរារាំងយ៉ាងធ្ងន់ធ្ងរទៅលើការអនុវត្តន៍សិទ្ធិមនុស្សរបស់ប្រជាជនកម្ពុជា។ លើសពីនេះទៅទៀត ការអនុវត្តន៍ដ៏គ្រោះថ្នាក់នេះ ជាការប៉ុនប៉ងយ៉ាងជាក់លាក់ចំពោះការតឹតត្បិតក្នុងបរិយាកាសបំពេញការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងជាការប៉ុនប៉ងដ៏ច្បាស់លាស់មួយក្នុងការបញ្ឈប់នូវសកម្មភាពនានារបស់ពួកគេ។

ហេតុដូច្នេះ ម.ស.ម.ក សូមលើកនូវអនុសាសន៍មួយចំនួនដែលរដ្ឋាភិបាលគួរ៖

- លុបចោលលិខិតដែលតម្រូវចុះហត្ថលេខាបែបនេះ ហើយចាត់ទុកលិខិតទាំងនោះជាមោឃៈ
- បញ្ឈប់ការអនុវត្តន៍ដោយបង្ខំលើអ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋ ដែលអនុវត្តនូវសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិនិងខាងការជួបប្រជុំតាមរយៈការចុះហត្ថលេខាលើលិខិតដែលរឹតត្បិតលើសិទ្ធិ ដើម្បីជាថ្នូរនឹងការដោះលែង ឬរួចផុតពីការចោទប្រកាន់
- បញ្ឈប់ជាបន្ទាន់នូវបម្រាមខុសច្បាប់នាពេលបច្ចុប្បន្ន ទៅលើការជួបប្រជុំ និងការធ្វើបាតុកម្មនានា
- បញ្ឈប់នូវរាល់ការយាយីផ្នែកនយោបាយ និងតាមផ្លូវតុលាការ និងអំពើហិង្សាប្រឆាំងនឹងអ្នកតវ៉ាដោយសន្តិវិធី និងការយាយីលើអ្នកការពារសិទ្ធិមនុស្ស និង
- ទទួលស្គាល់ពីសារៈសំខាន់របស់អ្នកការពារសិទ្ធិមនុស្ស និងអង្គការសិទ្ធិមនុស្ស ព្រមទាំងតម្រូវការក្នុងការការពារពួកគេ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងអ្នកការពារសិទ្ធិមនុស្សរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ៖ ០១៧ ៥២៨ ០២១ ឬតាមរយៈអ៊ីម៉ែល៖ chhunly.chhay@cchrcambodia.org ឬលោកស្រី អេលីស ធីលែត តាមរយៈទូរសព្ទ៖ +៨៥៥(០) ៧៧ ៧០ ៩៧ ២៣ ឬអ៊ីម៉ែល៖ elise.tillet@cchrcambodia.org។